មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៦-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១៦ ស្តីពីការតែងតាំង ឯកឧត្តម **ទៀន ហុង** ជាឧបការីសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៥៩

២៦-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១៧ ស្តីពីការតែងតាំង ឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ១៦០

២៦-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ជុង មួងស៊ីក** (JUNG MYUNG SIK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្ត ក្វាងជូ សាធារណរដ្ឋកូរ៉េ ១៦១

២៦-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **គីម យ៉ាងស៊ុក** (KIM YANG SOOK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្ត យ៉ៅស៊ូ ជុនរ៉ាណាំឌូ សាធារណរដ្ឋកូរ៉េ ១៦២

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៨ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **លី គឹមឡុង** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ១៦៣

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៩ ស្តីពីការប្រោសព្រះរាជទាន ចំពោះឧកញ៉ា **ហាក់ ម៉ុនឡើន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១៦៤

០៦-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០០១ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ និងអស់លោក ចំនួន ៤០ រូប ១៦៥

០៩-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០០២ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី **ឆាន់ វឌ្ឍនៈ** ជានាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ១៦៨

០៩-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០០៣ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ១៦៩

០៩-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០០៤ ស្តីពីការប្តូរឈ្មោះមុខតំណែងឯកឧត្តម **សាន ស៊ីថន** ពីនាយកវិជ្ជាស្ថានជាតិស្ថិតិ ទៅជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ១៧០

០៩-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០០៥ ស្តីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តម ០២ រូប ១៧១

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

១០-០១-២០០៦ -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៧២

១០-០១-២០០៦ -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៧៣

១០-០១-២០០៦ -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៧៤

១១-០១-២០០៦ -អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពីការតែងតាំង និង ផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ ១៧៥

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១១-០១-២០០៦ -ប្រកាសលេខ ០៣២ សហវ.ប្រក ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធីកាត់បន្ថយអត្រាពន្ធគយ នៃផ្នែកទីបីរបស់បញ្ជីដកចេញបណ្តោះអាសន្ន ១៧៧

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១១-០១-២០០៦ -ប្រកាសលេខ ០១៧ ឧរថ.កឧប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឡូទុសតិចស្តាយ ហ្គាមេន (ខេមបូឌា) បង្កើតសាខារោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ឡូទុសតិ តិចស្តាយ ហ្គាមេន (ខេមបូឌា)សាខា ទី ១" ១៧៩

១១-០១-២០០៦ -ប្រកាសលេខ ០១៨ ឧរថ.កឧប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ថៃរ៉ុង (ខេមបូឌា) នីតធីង បង្កើតរោងចក្រ "ផលិតស្រោមជើង" ដែលមានឈ្មោះថា " ថៃរ៉ុង (ខេមបូឌា)នីតធីង " ១៨១

១១-០១-២០០៦ -ប្រកាសលេខ ០១៩ ឧរថ.កឧប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន បូរិក ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " បូរិក ហ្គាមេន (ខេមបូឌា)" ១៨៣

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី

១០-០១-២០០៦ -ប្រកាសលេខ ០០១ កកន.ប្រក ស្តីពីការបង្កើតការិយាល័យចំណុះមន្ទីរកិច្ចការនារីខេត្ត-ក្រុង ១៨៥

៤_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

០៣-០១-២០០៦ -លិខិតលេខ ០០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌី.ជី (ខេមបូឌា)** ១៩០

០៣-០១-២០០៦ -លិខិតលេខ ០០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហេង យាង អ៊ឹមផត អិចផត** ១៩២

០៣-០១-២០០៦ -លិខិតលេខ ០០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តិក ប្រូហ្វេសិនណល តិធីអុី អិលធីឌី** ១៩៤

០៣-០១-២០០៦ -លិខិតលេខ ០០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជេ វ៉ាយ អេស ឆាយយើរ អ៊ិនធើណេសិនណល គ្រុប** ១៩៦

០៣-០១-២០០៦ -លិខិតលេខ ០០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ចើរ យូរៀ អ៊ិនធើណេសិនណល អ៊ិន** ១៩៨

០៣-០១-២០០៦ -លិខិតលេខ ០០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌី_អុី ស្ទីល ខបតើរេសិន** ២០០

០៣-០១-២០០៦ -លិខិតលេខ ០១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យ៉ុង សេ** ២០២

០៣-០១-២០០៦ -លិខិតលេខ ០១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ពេជ្រ ប៊ីយូធី** ២០៤

០៣-០១-២០០៦ -លិខិតលេខ ០១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សល ជីម៉ុន គ្រុប** ២០៦

០៣-០១-២០០៦ -លិខិតលេខ ០១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **មេនិនី (ខេមបូឌា)** ២០៨

០៣-០១-២០០៦ -លិខិតលេខ ០៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឃែតថល (ខេមបូឌា)** ២១០

០៣-០១-២០០៦ -លិខិតលេខ ០៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អែលថេក អេនើជី (ខេមបូឌា)** ២១២

០៣-០១-២០០៦ -លិខិតលេខ ០៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី អិម ប៊ី ស៊ី** ២១៤

០៣-០១-២០០៦ -លិខិតលេខ ០៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ីន ហ្វាង (ខេមបូឌា) ហ្គាមេន មេនូហ្វេកឈើរីង** ២១៦

០៣-០១-២០០៦ -លិខិតលេខ ០៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឆៀន ស៊ាង** ២១៧

០៤-០១-២០០៦ -លិខិតលេខ ០៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ ខេ ជេ ស៊ី អ៊ិនជីនារីង&ត្រេឌីង** ២១៩

០៥-០១-២០០៦ -លិខិតលេខ ០៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អិល_ខេ_អេហ្វ ខូ អិលធីឌី** ២២១

០៥-០១-២០០៦ -លិខិតលេខ ០៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ូឡូ ភ្លីប អិលធីឌី** ២២៣

០៥-០១-២០០៦ -លិខិតលេខ ០៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌី ហ្វ្រាន អ៊ិនធើណេសិនណល ភីឌីអ៊ី អិលធីឌី** ២២៥

០៥-០១-២០០៦ -លិខិតលេខ ០៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេស៊ា ហ្គាដិន** ២២៦

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0៧០៤/00១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២00៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ម៉ែន ហ្វុង ជាឧបការីសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥១២.៥៥៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ៖ ៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

១- ឯកឧត្តម ស៊ួន ហ្វួងស្រ៊ួន ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

២- ឯកឧត្តម ឡុង ធនចន្ទ្ន៍ ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

៣- ឯកឧត្តម នឹង យ៉ោយ៉េន ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧ល.០៥១៧.៥៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ១៧ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា ឆ្នាំថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

១- ឯកឧត្តម ស្វ៊ន ហុងស្រ៊ុន ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

២- ឯកឧត្តម ឡុង ធនចឡន៍ ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

៣- ឯកឧត្តម នឹង យ៉េវយ៉េន ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៥១២.៥៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ១៧ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

នស/រកត/១២០៥/៥១៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ជុង ម្យុងស៊ីក (JUNG MYUNG SIK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៤៤ នៅខេត្ត ក្វាងជូ (Gwang Ju) សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ៤៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង តាន់

៣រល.០៤១២.៥៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី គីម យ៉ាងស៊ុក (KIM YANG SOOK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៥៨ នៅខេត្ត យ៉ោស៊ូ ជុនរ៉ាណាំឌូ (Yeo Su, Jun Ra Nam Do) សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ៤៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង ឌី តាន់

តាក.០៥១២.៥៥៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លី គឹមឡុង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស-០៥១២.៥៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ១៤ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥៤៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា **ហាក់ ម៉ុនធឿន**

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ.០៩១០.៥៦៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខៈ ០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឆាយ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម ស៊ុំ សំណាង

-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

២-ឯកឧត្តម ហ៊ីវ សុវណ្ណ

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

៣-ឯកឧត្តម ជួន សុវណ្ណ

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

៤-ឯកឧត្តម ពេជ្រ គីមស្រ៊ាង

៥-លោកជំទាវ ផេង គន្ធាបូរី

៦-លោកជំទាវ ឡោក ខេង

៧-ឯកឧត្តម អ៊ី ឆន

៨-ឯកឧត្តម ជា សឿន

៩-ឯកឧត្តម ថៃ ទីណូ

១០-ឯកឧត្តម វិញ ហ៊ួរ

១១-ឯកឧត្តម សោម សឿន

១២-ឯកឧត្តម តាក ស៊ុនអ៊ី

១៣-ឯកឧត្តម ម៉ា ស៊ុនហួត

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

១៤-លោកជំទាវ កែវ ម៉ាលី

១៥-លោកជំទាវ សុភ័ក្ត ថាវី

១៦-ឯកឧត្តម ប៊ូ យឿង

១៧-ឯកឧត្តម សុខ សាយ

១៨-ឯកឧត្តម សុខ ណោ

១៩-ឯកឧត្តម គីម សុវណ្ណ

២០-ឯកឧត្តម គីម ណាំង

២១-ឯកឧត្តម ហែម សាមិន

២២-ឯកឧត្តម ហ៊ី ធាវី

២៣-ឯកឧត្តម រស់ វណ្ណា

២៤-ឯកឧត្តម យិន សាក់ន់

២៥-ឯកឧត្តម លឹម ហ៊ុយឡេង

២៦-ឯកឧត្តម ឡុច សារ៉េត

២៧-ឯកឧត្តម ទូច ឡេង

២៨-ឯកឧត្តម ម៉ែន ដែន

២៩-ឯកឧត្តម ជ្រាង សុផាន់

៣០-ឯកឧត្តម ជីវ សុងហាក់

៣១-ឯកឧត្តម ញ៉ែម សារ៉ន

៣២-ឯកឧត្តម ជា សុមេធី

៣៣-ឯកឧត្តម ប៉ក់ វិជិត

៣៤-លោកជំទាវ ជា សុផាម៉ាដែន

៣៥-ឯកឧត្តម យិន គីមអាន

៣៦-ឯកឧត្តម ឡាវ វ៉ាន់

៣៧-លោក សុត រស្មី

៣៨-លោក ជា ធា

៣៩-លោក ហួន សារឿន

៤០-លោក ឈុន គឹមស៊្រុន

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០៦

គួរព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រស.០១០១.០០១

លេខៈ ១០- ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

ព្រះរាជក្រឹត្យ

យើង

នស/រកត/០១០៦/០០២

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនឧត្តមសេនីយ៍ត្រី **ឆាន់ ចន្ថុនៈ** អត្តលេខ ០០៣៣៧២ ជានាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣៧៣.០៦០១.០០២

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ: ១៦. ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែមករាឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១-វរសេនីយ៍ឯក **យូ សិរីវុឌ្ឍ** អត្តលេខ ០១៩៧០៣

២-វរសេនីយ៍ឯក **ជួន រ៉ា** អត្តលេខ ០០២៣២៩

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រល.០៦០១.០០៣
លេខ: ៦១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ារ៉ាលី
ណារ៉ុន សន

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានប្តូរឈ្មោះមុខតំណែងឯកឧត្តម **សន ស៊ីថន** ពីនាយកវិជ្ជាស្ថានជាតិស្ថិតិ ទៅជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល-០៦០១.០០៤

លេខៈ ៣៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ឯកឧត្តម ឡាយ ទី

២-ឯកឧត្តម គង់ ធ្វើន

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៦

ជួនព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣៣ល-០៦០១-០០៥

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខៈ ១៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងវិស័យសិក្សាធិការ ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

១-ឧកញ៉ា **ស៊ឹម វណ្ណា**	អគ្គនាយកចំការកៅស៊ូបឹងកេត	ថវិកាចំនួន ៤១.៣៧០.០០០៛
២-លោក **កែវ សុឃាង**	ប្រធានការិ.ស្រាវជ្រាវនិងបង្ក្រាបអំពើគេចពន្ធ	ថវិកាចំនួន ៤៣.០០០.០០០៛
៣-លោក **ហ៊ួយ ស៊ុនេត**	ជំនួយការ.ស្រាវជ្រាវអំពើគេចពន្ធ	ថវិកាចំនួន ៤១.២៩០.០០០៛
៤-លោក **សុខ្ន ស៊ីន**	អភិបាលរង ខេត្តព្រៃវែង	ថវិកាចំនួន ៤២.៨៥៧.៣០០៛
៥-លោក **ឈួន សឿន**	ប្រធានមន្ទីរអប់រំ ខេត្តព្រៃវែង	ថវិកាចំនួន ៤១.៧៣១.៩០០៛
៦-លោក **ឈឿន មុន្នី**	ជំនួយការឯកឧត្តមឧប. ស ខេង	ថវិកាចំនួន ៤១.២១០.៥០០៛
៧-ឧកញ៉ា **ជ្រាង សុផាន់**	ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា	ថវិកាចំនួន ៤០.២៤០.២០០៛

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ... មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ចំនួន ០២គ្រឿង ថ្វាយ និងជូននាយក នាយករងគំរោងគាំទ្រវិស័យសូត្រ ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការ សំរាប់អនុវត្តគំរោងគាំទ្រវិស័យសូត្រមាសរបស់ខ្មែរ នៅខេត្តសៀមរាប ដែលមានទឹកប្រាក់ចំនួន ៣លាន អឺរ៉ូ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

១-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ តានុវត្តន៍** នាយកគំរោងគាំទ្រវិស័យសូត្រ ខេត្តសៀមរាប

២-លោក **អាល់ប៊ែរ ហ្វារ៉ាត់** (ALBERT -FARATS) នាយករងគំរោង និងជាប្រធានក្រុមអ្នកជំនួយការបច្ចេកទេស

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ចំនួន០៩គ្រឿង ជូនមន្ត្រីរាជការបំរើការងារក្នុងគំរោងគាំទ្រវិស័យសូត្រ នៅខេត្តសៀមរាប ដែលមានស្នាដៃល្អក្នុងការអនុវត្តន៍គំរោង និងលើកកំពស់ផលិតផលសូត្រមាស របស់ខ្មែរ ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសការងារ :

-លោក កែ មុន្នី អ្នកសំរបសំរួលគំរោងគាំទ្រវិស័យសូត្រភាគខាងត្បូង

ខ.មេដាយប្រាក់ការងារ :

១-លោក អ៊ុក ណារុធ អ្នកទទួលបន្ទុកការងារបច្ចេកទេសជាំមូន
២-លោកស្រី ឡុញ សុខវួច អ្នកទទួលបន្ទុកការងារសេដ្ឋកិច្ច
៣-លោក សាន ជាវាទ្ធា អ្នកទទួលបន្ទុកការងារបណ្តុះបណ្តាល
៤-លោក គីម ឡុង អ្នកទទួលបន្ទុកការងារវិភាគសេដ្ឋកិច្ច
៥-លោក មុត សារឿន អ្នកទទួលបន្ទុកការងារគណនេយ្យ
៦-លោក ជឹម តារាក្ស អ្នកទទួលបន្ទុកគំរោងគាំទ្រវិស័យសូត្រតំបន់ភ្នំស្រុក
៧-លោក អាំង សុផល អ្នកទទួលបន្ទុកគំរោងគាំទ្រវិស័យសូត្រតំបន់សំរោង
៨-លោក មី គីមតិក អ្នកទទួលបន្ទុកគំរោងគាំទ្រវិស័យសូត្រតំបន់ថ្មពួក

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំង និង ផ្លាស់ប្តូរគោរកិច្ចមន្ត្រីរាជការ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្ម មាត្រា ៤, មាត្រា ១០, នឹងមាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦អនក្រ/ បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ១០០អនក្រ/បក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្ម ជំពូកទី ៤, ជំពូកទី ៥, ជំពូកទី ៦, ជំពូកទី ៧, ជំពូកទី ៨, ជំពូកទី ១៣, នឹងជំពូកទី១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ/បក ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

សំ រេ ច

មាត្រា១ : ត្រូវតែងតាំង និងផ្លាស់ប្តូរភារកិច្ចមន្ត្រី នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដូចខាងក្រោម :

១.លោក ថៅ ជេដ្ឋា ជាប្រធាននាយកដ្ឋានបទប្បញ្ញត្តិ និងត្រួតពិនិត្យ

២.លោក នេត សុដល ជាប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងភស្តុភារ

៣.លោក ចាន់ រដ្ឋា ជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចសង្គមនិងគ្រប់គ្រងទិន្នន័យ

៤.លោក យ៉ិន ចំនួទាសនា ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

មាត្រា២ : រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីន សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាម៉ីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦

ហ៊ុន សែន

<u>ចម្លងជូន</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ០១ និង មាត្រា ០៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧២ សហវ.ប្រក

ប្រកាស
ស្តីពី
ការអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធីកាត់បន្ថយអត្រាពន្ធគយ នៃផ្នែកទីបីរបស់បញ្ជីដកចេញបណ្តោះអាសន្ន

....

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញភាពចាំបាច់ក្នុងការបំពេញកាតព្វកិច្ច ដែលមានចែងនៅក្នុងពិធីចូលរួមអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ដែលបានចុះហត្ថលេខា នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

- បានឃើញលិខិតលេខ ៦២៤៦ សហវ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការផ្ទេរផ្នែកទី ៣ ពីបញ្ជីដកចេញបណ្តោះអាសន្ន (Temporary Exclusion List) ទៅក្នុងបញ្ជីដាក់បញ្ចូល (Inclusion List) និង ការសំរេចរបស់ សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

សំរេច

ប្រការ១ : ប្រកាសឱ្យប្រើប្រាស់កម្មវិធីកាត់បន្ថយអត្រាពន្ធគយដូចមានចែងលំអិតនៅក្នុងបញ្ជីទំនិញដាក់បញ្ចូល នៃការផ្ទេរផ្នែកទី ៣ ពីបញ្ជីដកចេញបណ្តោះអាសន្ន តាមការសំរេចរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥ លើការអនុវត្តន៍កិច្ចព្រមព្រៀង CEPT សំរាប់ AFTA ។

ប្រការ២ : ដើម្បីប្រសិទ្ធភាពនៃការអនុវត្តន៍កាតព្វកិច្ចនានាដែលមាននៅក្នុងកិច្ចព្រមព្រៀង CEPT ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញប្រកាសណែនាំជាបន្តបន្ទាប់ ។

ប្រការ៣ : ប្រកាសនេះ ចាប់មានប្រសិទ្ធភាពអនុវត្ត ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦

គាត ឈន់

ចម្លងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន ខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ០១៧/០៦ ឧរថ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦

ប្រ កា ស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ៖
- បានឃើញប្រកាសលេខ ០៨២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី ០១.០២.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២២៦៨/០៥ គ.វ.ក ចុះថ្ងៃទី ១១.០៧.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ឡូទុសតិ៍ តិចស្តាយ ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២១.១២.២០០៥

ស ម្រ េ ច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ឡូទុសតិ៍ តិចស្តាយ ហ្គាមេន (ខេមបូឌា) (LOTUS TEXTILE GARMENT (CAMBODIA) CO., LTD.)តំណាងដោយលោក YUAN CHIEH សញ្ជាតិចិន(តៃវ៉ាន់) អាយុ៤៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200684079 ចុះថ្ងៃទី២៣.០៤.២០០៣ បង្កើតសាខារោងចក្រ“កាត់ដេរសម្លៀកបំពាក់” ដែលមានឈ្មោះថា “ ឡូទុសតិ៍ តិចស្តាយ ហ្គាមេន (ខេមបូឌា) សាខាទី១ (LOTUS TEXTILE GARMENT (CAMBODIA)No1)”មានទីតាំងស្ថិតនៅ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២: ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-ម៉ាស៊ីន និង លិខិតអនុញ្ញាតសាងសង់មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល០២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ឡូទុសតី តិចស្តាយ ហ្គាមេន(ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ-សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ០១ ម៉ាន ករ/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥០៧៣/០៥ គ.វ.ក ចុះថ្ងៃទី ២១.១២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ថៃរ៉ុង (ខេមប៊ូឌា)នីតធីង ចុះថ្ងៃទី១៥.១២.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ថៃរ៉ុង (ខេមបូឌា)នីតធីង (TAIRONG (CAMBODIA) KNITTING CO., LTD.) តំណាងដោយ លោក LIU XUNLIN សញ្ជាតិចិន អាយុ៣២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G12055238 ចុះថ្ងៃទី ០៤.០៣.២០០៥ បង្កើតរោងចក្រ "ផលិតស្រោមជើង" ដែលមានឈ្មោះថា " ថៃរ៉ុង (ខេមបូឌា) នីតធីង (TAIRONG (CAMBODIA) KNITTING)" មានទីតាំងស្ថិតនៅភូមិថ្នើក ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ “ផលិតស្រោមជើង” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន ថៃរ៉ុង (ខេមបូឌា) នីតធីង ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកណ្តាល

  “ ដើម្បីជូនជ្រាប ”
- ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ០១៩១៨ ឧរ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣២៧/០៥ គ.រ.ក ចុះថ្ងៃទី ២៧.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន បូរិក ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី១៨.១១.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន បូរិក ហ្គាមេន (ខេមបូឌា) (BORIC GARMENT (CAMBODIA) CO., LTD.) តំណាង ដោយលោក NG YUEN KWAN សញ្ជាតិចិន អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H90059892 ចុះថ្ងៃទី១៣.១០.១៩៩៨ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "**បូរិក ហ្គាមេន (ខេមបូឌា)(BORIC GARMENT (CAMBODIA)**" មានទីតាំងស្ថិតនៅ តាមផ្លូវជាតិលេខ៤ ភូមិព្រៃបឹង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល។

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ ៤៤៨ ផក.ប្រក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ និងលិខិតលេខ ៨២៨ ឧរថកឧ.លស ចុះថ្ងៃទី០៦.០៦.២០០២ ស្តីពីការសុំប្តូរទីតាំង របស់ក្រុមហ៊ុន យូ ឆេង ហ្គាមេនស៍ (YOU CHENG GARMENTS CO., LTD. របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន ប៊ូរិក ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១១: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាប "

- ដូចប្រការ ១០ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង កិច្ចការនារី

លេខ ......០០១..... កកន/ប្រក

ប្រកាស
ស្តីពី
ការបង្កើតការិយាល័យចំណុះមន្ទីរកិច្ចការនារី ខេត្ត-ក្រុង

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណូមពរការងារចាំបាច់ ។

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតមន្ទីរកិច្ចការនារី ខេត្ត - ក្រុងជាពីរប្រភេទ សំរាប់ទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួងដែលបានកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ។

១ - ប្រភេទ " ក " សំរាប់ខេត្ត ទាំង ១៣ គឺ ខេត្តកណ្តាល, ខេត្តកំពង់ស្ពឺ, ខេត្តតាកែវ, ខេត្តកំពង់ឆ្នាំង, ខេត្តព្រៃវែង, ខេត្តកំពង់ចាម, ខេត្តស្វាយរៀង, ខេត្តកំពត, ខេត្តពោធិសាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប និងខេត្តកំពង់ធំ ។

២ - ប្រភេទ " ខ " សំរាប់ខេត្ត -ក្រុងទាំង ១១ គឺ រាជធានីភ្នំពេញ, ក្រុងប៉ៃលិន, ក្រុងព្រះសីហនុ, ក្រុងកែប, ខេត្តឧត្តមានជ័យ, ខេត្តព្រះវិហារ, ខេត្តស្ទឹងត្រែង, ខេត្តក្រចេះ, ខេត្តរតនៈគិរី, ខេត្តមណ្ឌលគិរី និងខេត្តកោះកុង ។

ប្រការ ២ : មន្ទីរកិច្ចការនារី ខេត្ត-ក្រុងទាំងពីរប្រភេទ (ដូចប្រការ ១) មានរចនាសម្ព័ន្ធដូចខាងក្រោម :

ក.មន្ទីរកិច្ចការនារីប្រភេទ " ក " មាន ០៨ ការិយាល័យ :

១- ការិយាល័យរដ្ឋបាល-បុគ្គលិក

២- ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់

៣- ការិយាល័យផែនការ និងស្ថិតិ

៤- ការិយាល័យសមភាពយេនឌ័រ

៥- ការិយាល័យ ព័ត៌មាន

៦- ការិយាល័យអភិវឌ្ឍសេដ្ឋកិច្ច

៧- ការិយាល័យការពារផ្លូវច្បាប់

៨- ការិយាល័យស្ត្រី និងសុខភាព-ស្ត្រី និងការអប់រំ

ខ. មន្ទីរកិច្ចការនារីប្រភេទ " ខ " មាន ០៦ ការិយាល័យ :

១- ការិយាល័យរដ្ឋបាល-បុគ្គលិក

២- ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់ -ផែនការ និងស្ថិតិ

៣- ការិយាល័យសមភាពយេនឌ័រ និងព័ត៌មាន

៤- ការិយាល័យអភិវឌ្ឍសេដ្ឋកិច្ច

៥- ការិយាល័យការពារផ្លូវច្បាប់

៦- ការិយាល័យស្ត្រី និងសុខភាព -ស្ត្រី និងការអប់រំ

ប្រការ ៣ : តួនាទី ភារកិច្ចជាក់ស្តែងរបស់ការិយាល័យនីមួយៗ អាស្រ័យដោយអង្គភាពពាក់ព័ន្ធរៀបចំឡើង និង លើកសំណើជូនរដ្ឋមន្ត្រីពិនិត្យ សំរេច ក្រោយពីបានទទួលឯកភាពពី អគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ។

ប្រការ ៤ : ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ ៥ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ គ្រប់ប្រធានមន្ទីរកិច្ចការនារីខេត្ត-ក្រុងត្រូវអនុវត្ត តាមប្រកាសនេះ ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៦

រដ្ឋមន្ត្រី

ឃឹង អន្ធាជាតិ

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៦
- ឯកសារ -កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ០០១ កកន/ប្រក ចុះថ្ងៃទី១០ ខែ មករា ឆ្នាំ ២០០៦

អង្គការលេខរបស់មន្ទីរកិច្ចការនារីខេត្ត-ក្រុង (ប្រភេទ ក)



ឧបសម្ព័ន្ធនៃប្រកាសលេខ ០០១ កកន/ប្រក ចុះថ្ងៃទី១០ ខែ មករា ឆ្នាំ ២០០៦

អង្គការលេខរបស់មន្ទីរកិច្ចការនារីខេត្ត-ក្រុង (ប្រភេទ ខ)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០ ០ ៦ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០៦

សេចក្តីជូនដំណឹង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឌី . ជី (ខេមបូឌា)**

D . G (CAMBODIA) Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8273/05P ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **យឿន មុត**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១០ E ផ្លូវលេខ ២៧១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក័រជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាផ្ទេរ និងចែកចាយទំនិញ

-សេវាយកក័រជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤៦៥ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហេង ឃាង អ៊ីមផត អិចផត**
HENG KHIENG IMPORT EXPORT Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8272/05P** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឆេង សុវណ្ណ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១២៥ ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

